# អភិបូជាអរព្រះគុណព្រះជាម្ចាស់សម្រាប់ខួប១២ជាអភិបាល
# ធ្វើនៅព្រះវិហារបងស្រីសម្រាត់ការម៉ែល
# ភ្នំពេញថ្មី ថ្ងៃទី២ ខែតុលា ឆ្នាំ២០២២
## “សក្ខីភាពនៃសេចក្តីស្រឡាញ់”

**អត្ថបទទី១៖ ហាបាគូក ១,២-៣, ២,២-៤**

ប្រសិនបើក្រមកដល់ ចូរទន្ទឹងរង់ចាំ។ ហាគ ២,៣

**អត្ថបទទី១៖ ធីម៉ូថេទី២ ១,៦-៨.១៣-១៤**

យើងទទួលវិញ្ញាណដែលផ្តល់កម្លាំង សេចក្តីស្រឡាញ់ និងចិត្តធូន់។ ២ធម ១,៧

**ដំណឹងល្អ៖ លូកា ១៧,៥-១០**

យើងខ្ញុំគ្រាន់តែជាអ្នកបម្រើធម្មតាប៉ុណ្ណោះ គឺយើងខ្ញុំបានបំពេញកិច្ចការដែលយើងខ្ញុំត្រូវធ្វើ។ លក ១៧,១០

បងប្អូនជាទីស្រឡាញ់

ថ្ងៃនេះ ខ្ញុំបានមកដល់អារាមការមែល ដើម្បីថ្វាយអភិបូជាអរព្រះគុណព្រះជាម្ចាស់សម្រាប់លោកអភិបាល សិលា ស្លួន ហាង្សលី ជាអភិបាលព្រះសហគមន៍ភូមិភាគកំពង់ចាម។ អរព្រះគុណព្រះជាម្ចាស់ សម្រាប់ខួប១២ឆ្នាំដែលខ្ញុំបានបន្តពីលោកអភិបាល អេមីល ធ្វើជាអភិបាលភូមិភាគភ្នំពេញ។ អរព្រះគុណព្រះជាម្ចាស់ សម្រាប់សន្តីតេរេសានៃព្រះកុមារយេស៊ូ ដែលយើងគោរពនៅថ្ងៃទី ១ ខែតុលា ណែនាំឲ្យយើងចូលនៅក្នុងខែនៃការប្រកាសដំណឹងល្អសម្រាប់ព្រះសហគមន៍របស់យើងនៅក្នុងពិភពលោក។ ជាពិសេសឆ្នាំនេះ សម្តេចប៉ាបបានអញ្ជើញយើងឲ្យយើងទៅជាសាក្សីនៃការប្រកាសដំណឹងល្អ សម្រាប់មនុស្សទាំងអស់។ អរព្រះគុណព្រះជាម្ចាស់ សម្រាប់ខែតុលាដែលយើងចាប់ផ្តើមរួមជាមួយព្រះនាងម៉ារី ជាពេលវេលាមួយសម្រាប់យើងជាគ្រីស្តបរិស័ទ ដើម្បីអធិដ្ឋានតាមព្រះមាលាថែមទៀត។ យើងដឹងថា ពេលយើងអធិដ្ឋានតាមព្រះមាលាយើងចូលជ្រៅនៅក្នុងអាថ៌កំបាំងនៃជីវិត នៃព្រះជន្មព្រះយេស៊ូគ្រីស្ត ដែលជាព្រះបុត្រា ដែលជាព្រះសង្គ្រោះរបស់យើង។

ដូច្នេះ ថ្ងៃនេះពេលមកដល់ការមែលយើងមានសន្តសន្តិយ៉ាងច្រើន ដែលណែនាំឲ្យជីវិតរបស់យើងចូលយ៉ាងជ្រៅនៅក្នុងព្រះហឫទ័យព្រះជាម្ចាស់ ដើម្បីធ្វើជាសាក្សីរបស់ព្រះជាម្ចាស់។ ខ្ញុំជឿថា ជាពេលវេលាមួយសម្រាប់ភូមិភាគភ្នំពេញរបស់យើងទាំងមូល ដើម្បីទទួលព្រះអំណោយទានពីព្រះវិញ្ញាណដ៏វិសុទ្ធ។ ព្រះអំណោយទានយ៉ាងពិសេស ដូចលោកប៉ូលបានរំលឹកនៅក្នុងអត្ថបទទីមួយថ្ងៃនេះ "**យើងបានទទួលព្រះអំណោយទាន គឺផ្តល់កម្លាំង សេចក្តីស្រឡាញ់ នឹងចិត្តធូន់ ដើម្បីណែនាំឲ្យយើងប្រកាសដំណឹងល្អ ឲ្យយើងប្រកាសសក្ខីភាព យើងមិនត្រូវខ្មាស់ យើងមិនត្រូវខ្លាចប៉ុន្តែតួនាទីរបស់យើង គឺធ្វើជាសាក្សីនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅក្នុងពិភពលោកនេះ**"។ ប៉ុន្តែថ្ងៃនេះយើងស្តាប់នៅក្នុងអត្ថបទគម្ពីរដំណឹងល្អ សម្រាប់យើងដែលជាអភិបាល សម្រាប់យើងដែលជាអ្នកបម្រើរបស់ព្រះជាម្ចាស់ គឺជាកម្លាំងមួយដែរ។ នៅពេលព្រះយេស៊ូមានព្រះបន្ទូលថា "**នៅពេលយើងបម្រើ យើងបម្រើដោយសារជាតួនាទីរបស់យើង**"។

តាមពិតថ្ងៃនេះ ខ្ញុំប្រើពែងកាលីសរបស់ខ្ញុំ ដែលខ្ញុំបានទទួលនៅពេលខ្ញុំទទួលអគ្គសញ្ញាតែងតាំងជាបូជាចារ្យ។ នៅក្រោមពែងកាលីសនេះ ខ្ញុំបានឆ្លាក់ឈ្មោះតាយាយឪពុកម្តាយខ្ញុំទាំងអស់ ប៉ុន្តែជាពិសេសនៅពេលខ្ញុំតែងតាំងជាបូជាចារ្យ ខ្ញុំបានឆ្លាក់ដោយសេចក្តីស្រឡាញ់។ នៅពេលខ្ញុំតែងតាំងជាលោកអភិបាល ខ្ញុំបានថែមថាដោយមានចិត្តបម្រើ។ តាមពិតថ្ងៃនេះ យើងបានស្តាប់អំពីអត្ថន័យបម្រើ គឺយើងបំពេញតួនាទីយើងតែប៉ុណ្ណឹង។ ហេតុនេះហើយ នៅពេលយើងបានយកចិត្តទុកដាក់ សម្រាប់ខ្ញុំ១២ឆ្នាំហើយ សម្រាប់លោកលី ទើបតែចាប់ផ្តើម សម្រាប់បងស្រី បូជាចារ្យទាំងអស់ អស់ប៉ុន្មានឆ្នាំហើយ សម្រាប់គណៈកម្មការ ការិយាល័យនៅក្នុងភូមិភាគភ្នំពេញអស់ប៉ុន្មានឆ្នាំហើយ។ ប៉ុន្តែ យើងត្រូវការពោលថា "**យើងខ្ញុំគ្រាន់តែជាអ្នកបម្រើធម្មតាប៉ុណ្ណោះ គឺយើងខ្ញុំគ្រាន់តែបានបំពេញកិច្ចការដែលយើងខ្ញុំត្រូវធ្វើប៉ុណ្ណោះ**"។

នេះណែនាំឲ្យយើង ដូចជាមានសមត្ថភាពដើម្បីដាក់ខ្លួនដែរ ជួនកាលយើងចង់ស្តាប់ពាក្យ អរគុណ យើងចង់ស្តាប់ពាក្យសរសើរ យើងចង់ទទួលរង្វាន់...។ ប៉ុន្តែថ្ងៃនេះ យើងដឹងថាតាមពិតនៅពេលយើងដើរតាមព្រះយេស៊ូ ចំណុចទី១ដែលសំខាន់បំផុតគឺដាក់ខ្លួន ជាអ្នកក្រខ្សត់ ជាអ្នកបម្រើដែលខិតខំបំពេញតួនាទីរបស់គាត់តែប៉ុណ្ណឹង។ ដូច្នេះ ថ្ងៃនេះដែលសម្តេចប៉ាបអញ្ជើញយើងឲ្យយើងចូលនៅក្នុងខែប្រកាសដំណឹងល្អ ដើម្បីឲ្យយើងធ្វើជាសាក្សីនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់យ៉ាងពិសេស។ យើងត្រូវការគិតពិចារណា **ទៅជាសាក្សីរបស់ព្រះជាម្ចាស់មានន័យដូចម្តេច? យើងធ្វើដូចម្តេច នៅក្នុងការប្រកាសដំណឹងល្អនៃជីវិតរបស់យើងប្រចាំថ្ងៃ?** យើងធ្វើសាក្សីនៃ

ដំណឹងល្អ លុះត្រាតែយើងយកជីវិតរបស់យើងភ្ជាប់នឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់។ យើងធ្លាប់និយាយច្រើនដងដែរ ឲ្យយើងគាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់ អត់ត្រូវការធ្វើអ្វីអស្ចារ្យប៉ុន្មានទេ។ ប៉ុន្តែ ជីវិតរបស់យើងត្រូវការភ្ជាប់ជាមួយព្រះជាម្ចាស់នៅក្នុងព្រះបន្ទូល ដែលយើងស្តាប់ពីមួយថ្ងៃទៅមួយថ្ងៃ។ **យើងធ្វើដូចម្តេចដើម្បីអនុវត្ត?**

ថ្ងៃនេះដែលយើងនឹកឃើញដល់សន្តីតេរេសា យើងដឹងថាសន្តីតេរេសាដែលជាឧបកានីសម្រាប់ការប្រកាសដំណឹងល្អ បានរស់នៅក្នុងអារាមការម៉ែលជាកន្លែងតូចតាចរបស់គាត់។ គាត់បានរស់នៅក្នុងជីវិតខ្លីទៀត ប៉ុន្តែនៅក្នុងពេលវេលាដ៏ខ្លីនោះ គាត់បានធ្វើដូចម្តេចដើម្បីភ្ជាប់នឹងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់។ នៅក្នុងការងារតូចតាចប៉ុន្តែគោលដៅរបស់គាត់ គំនិតរបស់គាត់ ទស្សនៈរបស់គាត់ គឺធ្វើដូចម្តេចដើម្បីភ្ជាប់នឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលណែនាំឲ្យក្នុងជីវិតរបស់ខ្ញុំផ្ទាល់ខ្លួនចេះស្រឡាញ់។ នៅជុំវិញគាត់សុទ្ធតែបងស្រី ដែលមានបងស្រីមួយចំនួនធ្វើឲ្យគាត់ឈឺក្បាល បងស្រីមួយចំនួនធ្វើឲ្យគាត់អស់កម្លាំង។ ប៉ុន្តែ គាត់ខិតខំស្រឡាញ់បងស្រី ជាពិសេសបងស្រីដែលពិបាកជាងគេសម្រាប់គាត់។ គាត់ធ្លាប់សរសេរថា បងស្រីដែលគាត់ចេះតែញញឹមដាក់ ចេះតែបម្រើ តាមពិតជាបងស្រីដែលធ្វើឲ្យគាត់អស់កម្លាំងមែនទែន។ ប៉ុន្តែ ប្រសិនបើបងស្រីដឹង របៀបដែលមាននៅក្នុងចិត្តគាត់ប្រហែលបងស្រីនោះភ្ញាក់ ប៉ុន្តែគាត់ខិតខំតស៊ូដើម្បីលះបង់ចោល ដើម្បីបូជាម្យ៉ាងនៅក្នុងជីវិតសាមញ្ញធម្មតារបស់គាត់ជាបងស្រី។

ដូច្នេះ ខ្ញុំគិតថាសម្រាប់យើងដែលជាគ្រីស្តបរិស័ទនៅក្នុងខែតុលានេះ ជាពេលវេលាដើម្បីគិតពិចារណាថែមទៀត **តើនៅក្នុងជីវិតយើងរស់នៅប្រចាំថ្ងៃ យើងធ្វើដូចម្តេចដើម្បីផ្តល់សក្ខីភាពនៃសេចក្តីស្រឡាញ់ធម្មតា?** ដោយជួយគេ ដោយលើកទឹកចិត្តគេ ដោយញញឹម ដោយធ្វើដំណើររួមជាមួយគ្នា។ ជាពិសេស នៅក្នុងខែតុលានេះខ្ញុំអញ្ជើញគ្រីស្តបរិស័ទនៅក្នុងភូមិភាគភ្នំពេញ៖

**ចំណុចទី១** អធិដ្ឋានថែមទៀតសម្រាប់ការត្រាស់ហៅ ដោយសារ ម្សិលមិញយើងរំភើបដែលយើងមានកូនខ្មែរមួយរូបក្លាយជាអភិបាលនៅក្នុងភូមិភាគកំពង់ចាម។ ប៉ុន្តែ កូនខ្មែរនេះបានកើតនៅក្នុងភូមិភាគភ្នំពេញ យើងបាត់លោកបូជាចារ្យម្នាក់នៅក្នុងភូមិភាគភ្នំពេញ ដែលបានជួយផ្តល់សក្ខីភាព បម្រើអស់ពីកម្លាំងកាយកម្លាំងចិត្ត។ និសិត្សទេវវិទ្យាល័យរបស់យើង អត់មានច្រើនប៉ុន្មានទេ យើងដឹងហើយយើងមានឧបដ្ឋាកបី យើងមានបីអ្នកដែលកំពុងរៀននៅបាំងកក។ ដូច្នេះ បងប្អូនជាទីស្រឡាញ់សូមអធិដ្ឋានថែមទៀត បងស្រីក៏នៅខ្វះការត្រាស់ហៅដែរ បងស្រីនានានៅក្នុងភូមិភាគភ្នំពេញក៏ដូចគ្នាដែរ លោកបូជាចារ្យភូមិភាគក៏ខ្វះដែរ។ ដូច្នេះ យើងត្រូវការអធិដ្ឋាន

ដើម្បីឲ្យការត្រាស់ហៅ អាចចូលនៅក្នុងដួងចិត្តយុវជនយុវនារី។ ប៉ុន្តែ អាចបានលុះត្រាតែយើងផ្តល់សក្ខីភាពនៃសេចក្តីស្រឡាញ់នៅក្នុងជីវិតយើងប្រចាំ។

**ចំណុចទី២** ខ្ញុំអញ្ជើញភូមិភាគភ្នំពេញនៅក្នុងខែតុលា ដើម្បីអធិដ្ឋានយ៉ាងពិសេសបំផុតសម្រាប់ក្រុមគ្រួសារគ្រីស្តបរិស័ទ។ ជួនកាល មានតែឪពុក មានតែម្តាយ មានតែប្តី មានតែប្រពន្ធដែលជាគ្រីស្តបរិស័ទមែន ប៉ុន្តែយើងថាជាក្រុមគ្រួសារគ្រីស្តបរិស័ទ។ នៅថ្ងៃទី២៣ ខែតុលា នេះនៅពេលយើងគោរពថ្ងៃអាទិត្យនៃការប្រកាសដំណឹងល្អ រួមជាមួយព្រះសហគមន៍ពិភពលោក ខ្ញុំបានរៀបចំទិវាគ្រួសារកាតូលិកសម្រាប់ភូមិភាគភ្នំពេញ។ ដូច្នេះ យើងចាប់ផ្តើមពីពេលនេះតទៅ ដើម្បីអធិដ្ឋានឲ្យក្រុមគ្រួសារធ្វើដំណើរនៅក្នុងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ជួនកាលមានទុក្ខលំបាក ជួនកាលមានគ្រោះថ្នាក់ ជួនកាលមានបញ្ហាពិតមែន។ ប៉ុន្តែ យើងដឹងថានៅក្នុងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ យើងអាចទៅមុខដើម្បីឲ្យមានក្រុមគ្រួសារកាតូលិករឹងមាំ។ នេះជាសរសរមូលដ្ឋានគ្រឹះនៃព្រះសហគមន៍ នៃសង្គមមែន។ សរសរគ្រឹះនៃព្រះសហគមន៍យើង ដើម្បីឲ្យព្រះសហគមន៍យើងមានជីវិតថែមទៀត នៅក្នុងអំណរសប្បាយនៃរៀបចំខ្លួនសម្រាប់ព្រះរាជរបស់ព្រះជាម្ចាស់។

**ចំណុចទី៣** ដើម្បីបំពេញតួនាទីរបស់យើងជាអ្នកប្រកាសដំណឹងល្អ ដែលផ្តល់សក្ខីភាពអំពីជីវិតរបស់ព្រះយេស៊ូគ្រីស្ត អ្វីដែលសំខាន់បំផុតគឺភ្ជាប់ជាមួយព្រះយេស៊ូផ្ទាល់។ ដើម្បីឲ្យបន្តិចម្តងៗព្រះយេស៊ូបានកែខ្លួនរបស់យើង ដើម្បីណែនាំឲ្យយើងទៅជាមនុស្សថ្មី។ ឲ្យយើងកើតថ្មីនៅក្នុងពិភពលោកនេះ នៅក្នុងសង្គមបច្ចុប្បន្ននេះ។ ដោយដឹងថា សង្គមរបស់យើងអត់សូវរវីរវល់ជាមួយព្រះជាម្ចាស់ទេ សង្គមរបស់យើងរវីរវល់ជាមួយតែសម្ភារៈនិយម រវីរវល់ជាមួយជីវិតប្រចាំថ្ងៃ...។ ពេលយើងធ្វើដំណើរសព្វថ្ងៃ យើងឃើញនៅតាមផ្លូវ មានផ្លូវថ្មី មានអាគារច្រើនទៅៗ... ពិតមែនដើម្បីមានគ្រួសារ ដើម្បីមានជីវិត។ ប៉ុន្តែ សំខាន់គឺយើងភ្ជាប់ជាមួយព្រះយេស៊ូ ដើម្បីឱ្យព្រះយេស៊ូណែនាំជីវិតរបស់យើងខាងក្នុងទៅជាជីវិតថ្មី។ កុំឲ្យយើងទីពឹងតែលើទ្រព្យសម្បត្តិនៃលោកិយ៍ផ្ទុយទៅវិញឲ្យយើងទីពឹងទៅលើព្រះយេស៊ូតែម្តង។

បងប្អូនជាទីស្រឡាញ់ សូមមើលឈើឆ្កាងដែលមាននៅក្នុងអារាមការមែល ឈើឆ្កាងធំណាស់ពេលយើងមើលឈើឆ្កាងនេះយើងឃើញអត់មានព្រះយេស៊ូ ដោយសារតាមប្រពៃណីអារាមការមែលគឺបងស្រីដែលបូជាជីវិតនៅលើឈើឆ្កាងនេះ រួមជាមួយព្រះយេស៊ូ។ សម្រាប់យើងដែលជាគ្រីស្តបរិស័ទ យើងត្រូវតែសម្លឹងមើលឈើឆ្កាងរហូត ដែលជាសញ្ញាសម្គាល់នៃជីវិតថ្មី ប៉ុន្តែជីវិតថ្មី

អាចទទួលលុះត្រាតែយើងលះបង់ចោល លុះត្រាតែយើងតស៊ូ លុះត្រាតែយើងទៅមុខនៅក្នុងគ្រប់បញ្ហា។ ដូចសន្តប៉ូល នៅពេលគាត់សរសេរលិខិតគាត់ជាប់ឃុំឃាំង ប៉ុន្តែគាត់ថាទោះបីគាត់ជាប់ឃុំឃាំងក៏ដោយ យើងត្រូវការបន្តធ្វើដំណើរដើម្បីឲ្យអំពើល្អឈ្នះ។ ឈើឆ្កាងដែលជាសញ្ញាសម្គាល់នៃអំពើឃោរឃៅ សញ្ញាសម្គាល់នៃទុក្ខលំបាកដ៏កំពូលបំផុត អាចទៅជាជីវិតដ៏ពិតប្រាកដមែន។ ដោយសារនៅពេលហ្នឹង ព្រះយេស៊ូបានឈ្នះសេចក្តីស្លាប់ បានឈ្នះអំពើឃោរឃៅទាំងអស់ ដើម្បីឲ្យជីវិតរស់ ប៉ុន្តែនេះយើងអាចធ្វើបានលុះត្រាតែយើងកែប្រែចិត្តគំនិតផ្ទាល់ខ្លួន។

ហេតុនេះហើយ ខ្ញុំចង់រំលឹកដល់បងប្អូនទាំងអស់ នៅក្នុងចម្លើយដែលភូមិភាគភ្នំពេញបានរៀបចំសម្រាប់សន្និបាត២០២៣ នៃព្រះសហគមន៍ពិភពលោក។ ចំណុចទី១ ដែលយើងបានសរសេរ គឺ **"ខ្ញុំផ្ទាល់ខ្លួនកែប្រែចិត្តគំនិត"** មុនយើងគិតទាំងអស់ យើងមាន១៣ចំណុចអំពីគ្រួសារ អំពីការប្រកាសដំណឹងល្អ អំពីយុវជន អំពីការត្រាស់ហៅ អំពីអន្តរសាសនា អំពីការសិក្សាកាតូលិក អំពីអប់រំជំនឿយើងមានច្រើនណាស់។ ប៉ុន្តែ អាចទៅមុខលុះត្រាតែយើងផ្ទាល់ខ្លួនចាប់ផ្តើមអង្គុយដើម្បីគិត **"ខ្ញុំជាគ្រីស្តបរិស័ទម្នាក់ ខ្ញុំធ្វើដូចម្តេចដើម្បីភ្ជាប់ជាមួយព្រះយេស៊ូដែលនៅលើឈើឆ្កាងនេះ"**។ យើងត្រូវការនឹកឃើញសន្តីតេរេសា ដូចខ្ញុំបានរំលឹកដល់លោកអភិបាល លី ពីម្សិលមិញ សន្តីតេរេសាដែលគិតអំពីការត្រាស់ហៅគាត់យ៉ាងច្រើន ទោះបីគាត់នៅក្នុងអារាមហើយ គាត់នឹកឃើញខ្ញុំចង់ធ្វើជាបូជាចារ្យ ខ្ញុំចង់ធ្វើជាសាសនទូត ខ្ញុំចង់ធ្វើជាគ្រីស្តទូត ខ្ញុំចង់ៗច្រើនណាស់។ ប៉ុន្តែ មានថ្ងៃមួយគាត់ភ្ញាក់ស្មារតីរបស់គាត់ ដោយសារនៅពេលហ្នឹងគាត់ឃើញ ខ្ញុំរកឃើញហើយ ការត្រាស់ហៅរបស់ខ្ញុំនៅព្រះសហគមន៍ ដែលជាមាតារបស់ខ្ញុំ គឺធ្វើជាសេចក្តីស្រឡាញ់។

ដូច្នេះ ឲ្យយើងគិត តើយើងជាគ្រីស្តបរិស័ទយើងធ្វើដូចម្តេច ដើម្បីចូលនៅក្នុងគំនិតនេះ យើងជាក្មេង យើងជាយុវជន ជាឪពុកម្តាយ ជាតាយាយ ការត្រាស់ហៅរបស់យើងនៅក្នុងព្រះសហគមន៍ដែលជាមាតារបស់យើងសំខាន់ណាស់ គឺធ្វើដូចម្តេចដើម្បីឲ្យយើងទៅជាសញ្ញាសម្គាល់ សាក្សីបន្ទាល់នៃសេចក្តីស្រឡាញ់ ឱ្យយើងគិតរៀងៗខ្លួន។ ថ្ងៃនេះ ជាពេលវេលាមួយដើម្បីអរព្រះគុណព្រះជាម្ចាស់ ក្នុងខែតុលានេះយើងពោរពេញដោយកម្លាំង ដោយសារយើងមានគម្រូ។ យើងមានសន្តសន្តីច្រើន ដែលជាគម្រូពិសេសដើម្បីឲ្យយើងទៅមុខ នៅក្នុងខែតុលាយើងគោរពសន្តីតេរេសា គោរពទេវទូតដែលការពារថែរក្សាយើង យើងគោរពសន្តប្រាំងស្វ័រនៃទីក្រុងអាស៊ីស៊ី យើងគោរពសន្តប្រុយណូ ដែលបានបង្កើតជីវិតសម្ងាត់ដែរ។

ក្រោយមក យើងគោរពសន្តយ៉ូហានទី២៣ ជាសម្តេចប៉ាបដែលបានណែនាំឲ្យព្រះសហគមន៍ភ្ជាប់ជាមួយព្រះវិញ្ញាណដ៏វិសុទ្ធនៅក្នុងមហាសន្និបាតវាទីកង់ទី២។ ថ្ងៃទី១៥ យើងគោរពសន្តីតេរេសាធំនៃទៅក្រុងអាវេឡា ដែលបានកែការមែលដើម្បីចាប់ផ្តើមចូលសាជាថ្មី នៅក្នុងជីវិតដែលព្រះជាម្ចាស់បានរៀបចំ តាមព្រះហឫទ័យរបស់ព្រះអង្គ។ ក្រោយមក យើងគោរពសន្តលូកា ដែលណែនាំឲ្យយើងមើលឃើញនៅក្នុងគម្ពីរដំណឹងល្អ ព្រះហឫទ័យប្រណីសន្តោសរបស់ព្រះជាម្ចាស់ និងណែនាំឲ្យយើងស្គាល់ជីវិតនៃដើមព្រះសហគមន៍គឺកិច្ចការគ្រីស្តទូត។ ថ្ងៃទី២២ ខែតុលា យើងគោរពសន្តយ៉ូហាន ប៉ូលទី២ ជាសម្តេចប៉ាបដែលណែនាំឲ្យពិភពលោកចាប់ផ្តើមមើលឃើញ ពិតមែនអទិភាពនៅក្នុងពិភពលោកគឺព្រះយេស៊ូផ្ទាល់។ ជាពិសេសតាមរយៈទិវាយុវជនពិភពលោក ណែនាំឱ្យយុវជនភ្ញាក់ឡើង ដើម្បីយល់ថាយើងជាទាហានរបស់ព្រះជាម្ចាស់ យើងជាគ្រីស្តទូតរបស់ព្រះជាម្ចាស់ ដើម្បីប្រកាសដំណឹងល្អនៅក្នុងជីវិតរបស់យើងគ្រប់ពេលវេលា ខ្ញុំជាយុវជនរបស់យ៉ូហានប៉ូលទី២។

ក្រោយមក យើងគោរពគ្រីស្តទូតស៊ីមននិងយូត ដែលណែនាំឲ្យយើងមើលឃើញជីវិតរបស់យើងសព្វថ្ងៃ បានចេញពីក្រុមគ្រីស្តទូត ដែលបានសុខចិត្តទៅប្រកាសដំណឹងល្អ តាមព្រះបង្គាប់របស់ព្រះយេស៊ូ "**សូមទៅប្រកាសដំណឹងល្អនេះ ដើម្បីឲ្យពិភពលោកស្គាល់ជីវិតដែលខ្ញុំបានណែនាំ គឺការសង្គ្រោះ ជីវិតអស់កល្បជានិច្ច**"។ យើងដឹងថាយើងអាចធ្វើបាន ដោយសារក្នុងខែតុលានេះ យើងមានព្រះនាងម៉ារី ដែលណែនាំឲ្យយើងចូលនៅក្នុងដំណើរជីវិតរបស់ព្រះយេស៊ូដើម្បីឲ្យយើងធ្វើដំណើរបន្តិចម្តងៗនៅក្នុងសេចក្តីសុខ ដែលព្រះជាម្ចាស់បានរៀបចំឲ្យ។ ហេតុនេះហើយ យើងមានឧបករណ៍ទាំងអស់ យើងមានមធ្យោបាយទាំងអស់ ដើម្បីចូលនៅក្នុងការប្រែផ្លូវវិញ្ញាណរបស់យើង។ មិនមែនកែប្រែចិត្តគំនិត ប៉ុន្តែឲ្យជីវិតវិញ្ញាណរបស់យើងកែប្រែ ដើម្បីឲ្យគ្រប់ថាមពលដែលយើងមាននៅក្នុងខ្លួន គ្រប់កម្លាំងដែលយើងមាននៅក្នុងខ្លួន គ្រប់សេចក្តីក្លាហានដែលយើងមាននៅក្នុងខ្លួន កុំឲ្យចេញតាមផ្លូវដែលអត់មានប្រយោជន៍។ ប៉ុន្តែ ឲ្យប្រើដើម្បីមើលឃើញព្រះជាម្ចាស់ នឹងដើម្បីបម្រើបងប្អូនឯទៀតៗ។ ទោះបីយើងជាអ្នកបម្រើដែលគ្មានប្រយោជន៍ យើងជាអ្នកបម្រើតែប៉ុណ្ណឹង ប៉ុន្តែយើងជាអ្នកបម្រើដោយដឹងថាគ្រប់កម្លាំង ថាមពលដែលយើងមាននៅក្នុងខ្លួន យើងកែប្រែដើម្បីប្រើសម្រាប់ព្រះជាម្ចាស់ ប្រើសម្រាប់បងប្អូនឯទៀតៗ។

បងប្អូនជាទីស្រឡាញ់ ថ្ងៃនេះខ្ញុំសូមអរព្រះគុណព្រះជាម្ចាស់សម្រាប់លោកអភិបាល លី ដែលជាអភិបាលថ្មីនៃភូមិភាគកំពង់ចាម។ ខ្ញុំចង់បង្ហាញការដឹងគុណដល់លោកអភិបាល ឆ្មារ សាឡាស់

ដែលយើងនឹកឃើញតាមរយៈឈើឆ្កាងនេះ។ ដល់លោកអភិបាល អ៊ីវ និងលោកអភិបាល អេម៉ីល ដែលបានបូជា លះបង់ចោលជីវិតសម្រាប់ព្រះសហគមន៍របស់យើងនៅប្រទេសកម្ពុជា។ ខ្ញុំសុំឱ្យបងប្អូនទាំងអស់អធិដ្ឋានសម្រាប់ខ្ញុំផ្ទាល់ សម្រាប់ភូមិភាគរបស់យើងផ្ទាល់ ឲ្យយើងបន្តធ្វើដំណើរ។ ឲ្យយើងទាំងអស់គ្នា យើងចម្រើនពរដើម្បីឲ្យយើងមានសេចក្តីសុខនៅក្នុងជីវិតផ្ទាល់ នៅក្នុងសង្គមបច្ចុប្បន្ននេះ យើងទូលអង្វរព្រះអង្គឲ្យព្រះអង្គគង់នៅជាមួយយើងជានិច្ច។ អាម៉ែន៕

+ លោកអភិបាល អូលីវីយេ ជ្មីតហាស្លេ
អភិបាលព្រះសហគមន៍កាតូលិកកម្ពុជា
ភូមិភាគភ្នំពេញ

https://youtu.be/9SCczapNKtI